**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខៈ........✓...........

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ឯកឧត្តម រដ្ឋមន្ត្រីការពារជាតិសឹង្ហបុរី សម្តេចពិជ័យសេនា **ទៀ បាញ់** **ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងការពារជាតិ នឹងដឹកនាំគណៈប្រតិភូយោធាជាន់ខ្ពស់ក្រសួងការពារជាតិ អញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានក្រៅផ្លូវការ (Asean Defence Ministers Meeting Retreat "ADMM Retreat") ពីថ្ងៃទី០៥ ដល់ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨ នៅសាធារណរដ្ឋសឹង្ហបុរី។

បន្ទាប់ពីកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានក្រៅផ្លូវការ(ADMM Retreat) សម្តេចពិជ័យសេនា **ទៀ បាញ់** ព្រមទាំងគណៈប្រតិភូយោធាជាន់ខ្ពស់ក្រសួងការពារជាតិ ក៏នឹងត្រូវបានអញ្ជើញចូលរួមផងដែរ ក្នុងកម្មវិធីពិពណ៌លំហរអាកាសសឹង្ហបុរី២០១៨ (Singapore Airshow 2018) ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៨។

កម្មវិធី Singapore Airshow 2018 គឺជាព្រឹត្តិការណ៍លម្ហអាកាស និងការពារជាតិធំជាងគេនៅអាស៊ី ដែលនាំមកនូវការប្រមូលផ្តុំជួបជុំ អ្នកដឹកនាំមន្ត្រីការពារជាតិជាន់ខ្ពស់ និងឧស្សាហកម្មការពារជាតិ ដើម្បីបង្ហាញនូវបច្ចេកវិទ្យាថ្មីៗចុងក្រោយនៃប្រព័ន្ធការពារអាកាស និងលើគោក ។

ថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា ឆព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១៨

នាយកដ្ឋានព័ត៌មាន